# បទពិសោធន៍នៃការបញ្ជ្រាប

# ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ

# ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍រាជធានី

# ខេត្ត ក្រុង ស្រុក ខណ្ឌ

# មាតិកា

១. សារិតា

២. លទ្ធផល

៣. បទពិសោធន៍ និង មេរៀនទទួលបាន

# ១. សាវតា

- NCDMបានខិតខំប្រឹងប្រែងធ្វើការជាមួយអង្គការជាតិ អន្តរជាតិ ដែលកំពុងធ្វើការលើការកាត់បន្ថយហានិភ័យនៃ គ្រោះមហន្តរាយ ដើម្បីកសាងសមត្ថភាពដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង ឃុំ ដើម្បីការបញ្ជ្រាបគ្រោះមហន្តរាយ ទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ និង ការរៀបចំកម្មវិធីវិនិយោគថ្នាក់ឃុំ ។
- NCDMក៏បានខិតខំប្រឹងប្រែងធ្វើការជាមួយក្រសួងផែនការ ដោយ ក្រសួងផែនការបានចូលរួម និង គាំទ្រយ៉ាងពេញលេ ដើម្បីជំរុញ អោយការបញ្ជ្រាបនេះផងដែរ តាមរយៈការផ្តល់ បណ្តុះបណ្តាល និង ការផ្តល់នូវការតំរង់ទិសដល់ក្រុមកសាង ផែនការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង ថ្នាក់ឃុំ ។



# ១. សាវតា

- នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង ឃុំ សង្កាត់ PCDM, DCDM and CCDM ក៏បានចូលរួមក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគនៅថ្នាក់ ធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង ឃុំ សង្កាត់ ដើម្បីជំរុញ ការបញ្ជ្រាបនេះផងដែរ ។

- មានការចូលរួម និង គាំទ្រយ៉ាងពេញលេញ ពីមន្ទីរផែនការ រាជធានី ខេត្ត និង កម្មវិធី គ.ជ.អ.ប ផងដែរ ជាពិសេស នៅថ្នាក់ជាតិ និង ថ្នាក់រាជធានី ខេត្ត លើការបញ្ជ្រាប នេះផងដែរ ។



# ២. លទ្ធផល

- ក្រសួងផែនការ និង អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិរបស់ គ.ជ.អ.ប បានបញ្ចូលការគ្រប់គ្រងគ្រោះមហន្តរាយ និង បំរែបំរួលអាកាសធាតុ ជា យុទ្ធសាស្ត្រមួយ នៅក្នុងសេចក្ដីណែនាំបច្ចេកទេសស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។

- នៅក្នុងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិយោគថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង ឃុំ សង្កាត់ មានលើកឡើងនូវ វិធានការណ៍ ឬ គំរោងទាក់ទងនឹងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និង ការបន្សុាំនឹងបំរែបំរួលអាកាសធាតុ។ តែមិនបានទូលំទូលាយនៅឡើយ



# ២. លទ្ធផល :

## កម្មវិធីវិនិយោគឃុំ ដែលទាក់ទងនឹងការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ នៅក្នុង៣ស្រុក ខេត្តព្រៃវែង




ស្រុកពាមរក៍ ស្រុកស៊ីធរកណ្តាល និង ស្រុកពាមជរ

→ គំរោងសរុប ៣៦៣

→ គំរោងអភិវឌ្ឍន៍ទូទៅ ២០៥ =៥៦%

→ គំរោងទាក់ទងនឹងការកាត់បន្ថយ គ្រោះ ភ័យនៃគ្រោះមហន្តរាយ ១៥៨ = ៤៤%

# ២. លទ្ធផល

## កម្មវិធីវិនិយោគឃុំ ដែលទាក់ទងនឹងការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ នៅក្នុង៣ស្រុក ខេត្តកណ្ដាល




ស្រុក ល្វាឯម ស្រុកលើកដែក និង កៀនស្វាយ

- គំរោងសរុប ៣៦៥
- គំរោងអភិវឌ្ឍន៍ទូទៅ ២២៧ = ៦៣ %
- គំរោងទាក់ទងនឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ១៣៨= ៣៧ %

# ប្រភេទគំរោង និង សកម្មភាពដែលទាក់ទងនឹងការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយ

## ផ្នែកសេដ្ឋកិច្ច

### បែបរូបវ័ន្ត

- ផ្លូវលំតភ្ជាប់ទៅកាន់ទួលសុវត្ថិភាព
- ទ្វារទឹក
- លូទឹក
- ប្រឡាយទឹក និង ប្រព័ន្ធស្រោចស្រព
- ស្ពាន
- ទីទួលសុវត្ថិភាពគ្រួសារនិង សហគមន៍
- ទំនប់ទឹក
- ទូកដល់គ្រួសារងាយរងគ្រោះដើម្បីប្រកបរបរចិញ្ចឹមជីវិត

### បែបអរូបវ័ន្ត

- បង្កើនសមត្ថភាពពីការគ្រប់គ្រងគ្រោះមហន្តរាយ
- ពូជស្រូវ និង ដំណាំដែលធន់អាកាសធាតុ និង មានរយ:ពេលខ្លី
- បង្កើនជំនាញពីការចិញ្ចឹមសត្វ និង ដាំដំណាំ

# ប្រភេទគំរោង និង សកម្មភាពដែលទាក់ទងនឹងការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយ

## ផ្នែកសង្គមកិច្ច

### បែបរូបវ័ន្ត

- កែលំអទីទូលសុវត្ថិភាពសហគមន៍អោយមានអណ្តូងទឹក និង បង្គន់
- លើកទីទូលសុវត្ថិភាពគ្រួសារ និង សហគមន៍
- ជីកស្រះទឹក
- ផ្តល់ធើងចំរោះទឹកស្អាត
- ពង្រឹងផ្ទះរបស់គ្រួសារងាយរងគ្រោះ (ក្រីក្រ)
- ផ្តល់ទូកជំលៀសសហគមន៍
- ទូកសំរាប់ប្រកបរបរចិញ្ចឹមជីវិត
- ធ្វើជំរកបណ្តោះអាសន្នសហគមន៍

### បែបអរូបវ័ន្ត

- អប់រំសុខភាព និង ការប្រើប្រាស់ទឹកស្អាត
- ផ្តល់ស្បៀងសង្គ្រោះបន្ទាន់
- ផ្តល់ថ្នាំពេទ្យ
- បណ្តុះបណ្តាលពីការសង្គ្រោះបឋម
- ផ្តល់ធើងចំរោះទឹក
- វិធានការសន្តិសុខសង្គម (ធនាគារស្រូវ ធនាគារគោ និង រៀបចំក្រុមជួយខ្លួនឯង)

# ប្រភេទគំរោង និង សកម្មភាពដែលទាក់ទងនឹងការកាត់បន្ថយ
# គ្រោះភ័យនៃគ្រោះមហន្តរាយ

## ផ្នែកការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន

### បែបរូបវ័ន្ត

— ស្តារបឹងធម្មជាតិ

— ដាំដើមឈើឡើងវិញ

— ជីកប្រលាយដោះទឹក

### បែបអរូបវ័ន្ត

— ថែរក្សា និង គ្រប់គ្រងព្រៃលិចទឹក

— ធ្វើចង្ក្រានប្រើឧស្ម័នធម្មជាតិ

— អប់រំពីច្បាប់នៃការគ្រប់គ្រងធនធានធម្មជាតិ

— ផ្តល់បច្ចេកទេសពីការប្រើជីគីមី និង ថ្នាំពុល

# ប្រភេទគំរោង និង សកម្មភាពដែលទាក់ទងនឹងការកាត់បន្ថយ
# គ្រោះភ័យនៃគ្រោះមហន្តរាយ

## ផ្នែករដ្ឋបាល និងសន្តិសុខ

### បែបរូបវ័ន្ត

— ទូកដើរល្បាតតាមផ្ទះប្រជាជន ដែលបានជំលៀសចេញ

— វិទ្យុទាក់ទង

### បែបអរូបវ័ន្ត

— ជំលៀសប្រជាជនដែលលិចលង់

— ការពារសន្តិសុខ និង សណ្តាប់ធ្នាប់កន្លែង ដែលប្រជាជនស្នាក់នៅ

# ប្រភេទគំរោង និង សកម្មភាពដែលទាក់ទងនឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

## ផ្នែកយេនឌ័រ

### បែបអរូបវ័ន្ត

- ធ្វើអោយមានការចូលរួមរបស់ស្ត្រី កុមារ មនុស្សចាស់ នៅក្នុងការធ្វើផែនការ និង ការអនុវត្តផែនការ
- បង្កើនសមត្ថភាពស្ត្រី និង កុមារពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

## ៣. បទពិសោធន៍ដែលទទួលបាន

→ **ការសហការជាមួយអង្គការដៃគូអភិវឌ្ឍន៍**

- ការបង្កើនសមត្ថភាពដល់មន្ត្រីរបស់អង្គការដៃគូដែលមានតួនាទីក្នុងការជួយ និង គាំទ្រដល់ មន្ទីរ និង ក្រុមប្រឹក្សាឃុំក្នុងការរៀបចំផែនការ ឬ កម្មវិធីវិនិយោគប្រចាំឆ្នាំ ឱ. មន្ត្រីសំរបសំរួលខេត្ត និង ស្រុករបស់ គ.ជ.អ.ប ជាការវិធីសាស្ត្រដែលមានប្រសិទ្ធិភាព ក្នុងការបញ្ជ្រាបវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន

- មន្ត្រីសំរបសំរួលថ្នាក់ខេត្ត និង ស្រុករបស់ គ.ជ.អ.ប ជាអ្នកបន្តបណ្តុះបណ្តាល ដល់ក្រុមប្រឹក្សាឃុំពីការរៀបចំកម្មវិធីវិនិយោគឃុំប្រចាំឆ្នាំ ដូច្នេះ នៅពេលដែលគេ បណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំពីការរៀបចំកម្មវិធីវិនិយោគ គេក៏អាចបណ្តុះបណ្តាលពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងពេលជាមួយគ្នានេះដែរ។

- នៅពេលដែល ក្រុមមន្ត្រីសំរបសំរួលថ្នាក់ខេត្ត និង ស្រុករបស់ គ.ជ.អ.ប សំរបសំរួលដល់ក្រុមប្រឹក្សាឃុំ ពីការរៀបចំកម្មវិធីវិនិយោគឃុំ ក៏គេអាចសំរបសំរួលក្នុងការបញ្ចូលវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងកម្មវិធីវិនិយោគឃុំផងដែរក្នុងពេលតែមួយ ។

# ៣. បទពិសោធន៍ដែលទទួលបាន

→ **ការគាំទ្រពីមន្ទីរ និង ក្រសួងផែនការ**

– ការធ្វើអោយមានការចូលរួម ដើម្បីផ្តល់បច្ចេកទេសពីក្រសួងផែនការ និង មន្ទីរផែនការខេត្ត ក៏ជាយន្តការដ៏មានប្រសិទ្ធិភាព ក្នុងការរៀបចំផែនការ និង ការបញ្ចូលវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងផែនការ អភិវឌ្ឍន៍មូលដ្ឋាន ដោយសារក្រសួង និង មន្ទីរផែនការ ជាអ្នកផ្តល់បច្ចេកទេស

→ **ការធ្វើអោយមានផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ នៅថ្នាក់ខេត្ត និង ស្រុក**

– ការធ្វើអោយមានផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ តាមវិស័យ ឬ តាមមន្ទីរ – អង្គភាព អោយស្របតាមកម្មវិធីស្នូលរបស់វិស័យនិមួយៗ ក៏ជាយន្តការដ៏មាន ប្រសិទ្ធិភាព ព្រោះផែនការនេះ នឹងត្រូវបានអនុវត្ត ដោយមន្ទី-អង្គភាព ចំនែក លេខាធិការដ្ឋានរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ គ្រាន់តែជាអ្នកសំរបសំរួល និង ផ្តល់បច្ចេកទេស។

## ៣. បទពិសោធន៍ដែលទទួលបាន

→ **ការធ្វើអោយមានការចូលរួមពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង ស្រុក**

— ការធ្វើអោយមានការចូលរួម ដើម្បីផ្តល់បច្ចេកទេសពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង ស្រុក នៅក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ តាំងពីជំហានទី ១ ដល់ជំហានទី ៥ ក៏ជាយន្តការដ៏មានប្រសិទ្ធិភាព នៅក្នុងការបញ្ជ្រាប វិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយដែរ ។ ព្រោះគណៈកម្មាធិការនេះ អាចជួយផ្តល់បច្ចេកទេសដល់ក្រុមប្រឹក្សាឃុំពីវិធានការកាត់បន្ថយគ្រោះភ័យនៃ គ្រោះមហន្តរាយ។

— ការផ្តល់ការបណ្តុះបណ្តាលដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង ការផ្តល់ឱកាសអោយគណៈកម្មាធិការនេះ បានចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍ដែលទាក់ទឹងការកាត់បន្ថយគ្រោះមហន្តរាយក៏ជាយន្តការមួយដ៏មានប្រសិទ្ធិភាពដែរ ដោយសារ ពួកគេអាចទទួលបានការយល់ដឹងពីគំនិតផ្តួចផ្តើមនានា